## ព្រឹត្តិបត្របច្ចេកទេស លេខ ៧៨

# ផែនការគ្រប់គ្រងព្រៃឈើ

ការគ្រប់គ្រងព្រៃឈើ គឺជា ការថែរក្សា គ្រប់គ្រង ប្រើប្រាស់ និងការពារព្រៃឈើក្នុងលក្ខណៈមួយសមស្រប ក្នុងគោលបំណងផ្តល់គុណប្រយោជន៍ដល់មនុស្សជាតិ ។ ផែនការគ្រប់គ្រងព្រៃឈើ ពឹងផ្អែកលើការធ្វើសារពើភ័ណ្ឌដែលមានផែនទីគូសបង្ហាញពីលក្ខណៈប្លែកគ្នារបស់តំបន់មួយណានោះ និងការបែងចែកប្រភេទដើមឈើ និងធនធានផ្សេងៗទៀត ។ ជាតួយ៉ាង ផែនការគ្រប់គ្រងព្រៃឈើ រួមបញ្ចូលទាំងអនុសាសន៍នៃការដាំកូនឈើ តារាងកាលវិភាគសម្រាប់ការប្រត្តិបត្តិ និងកម្រៃសេដ្ឋកិច្ច ។

សម្រាប់អ្នកគ្រប់គ្រងព្រៃឈើ ការគ្រប់គ្រងព្រៃឈើដោយមាននិរន្តភាពនៅកន្លែងណាមួយ មានន័យថា ការកំណត់ជាក់ស្តែងនូវរបៀបនៃការប្រើប្រាស់វានាពេលបច្ចុប្បន្ន ដើម្បីធានាបានថាផលប្រយោជន៍ ឬ ផលកំរៃ ទាំងផ្នែកសុខភាព និងផលិតភាពរបស់ព្រៃឈើមានភាពប្រសើរជាងនាពេលអនាគត ។ អ្នកគ្រប់គ្រងព្រៃឈើត្រូវតែប៉ាន់ប្រមាណ និងធ្វើសមាហរណកម្មដ៏ធំទូលាយមួយនៅពេលដែលមានកត្តាប្រឆាំងគ្នា មួយចំនួនដូចជា តម្លៃផ្នែកពាណិជ្ជកម្ម (ដែលអាចដោះដូរជាលុយ) និងក្រៅពាណិជ្ជកម្ម (ដែលមិនអាចដោះដូរជាលុយ) ក៏ដូចជាការពិចារណាទៅដល់បញ្ហាបរិស្ថាននានា ដើម្បីបង្កើតផែនការគ្រប់គ្រងព្រៃឈើសមស្រប ។ ដោយហេតុថាព្រៃឈើ និងសង្គមមានការផ្លាស់ប្តូរពីពេលមួយទៅពេលមួយ លទ្ធផលនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពដែលយើងចង់បាន ក៏មិនអាចស្ថិតនៅតែដដែលរហូតនោះដែរ ។ អ្វីដែលជានិយមន័យនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព នឹងមានការផ្លាស់ប្តូរទៅតាមពេលវេលា និងទៅតាមការប្រែប្រួលជាសាធារណៈ ។

## ការគូសផែនទីធនធានព្រៃឈើ និងការធ្វើសារពើភណ្ឌ

គោលបំណងនៃការគូសផែនទីធនធានព្រៃឈើ និងការធ្វើសារពើភ័ណ្ឌ គឺដើម្បីកំណត់ប្រភេទ និង គុណភាពព្រៃឈើ និងឈើដែលនឹងប្រមូលផលនៅក្នុងតំបន់កំណត់ណាមួយ ។ ដំណើរការនេះពាក់ព័ន្ធនឹងការកំណត់ និងទីតាំងព្រំប្រទល់តាមលក្ខណៈធម្មជាតិ (ជ្រលងភ្នំ អូរ) ហេដ្ឋារចនាសម្ព័ន (ផ្លូវរទេះ ផ្លូវដើរ) ផ្លូវទឹក និងលក្ខណៈធម្មជាតិមួយចំនួនទៀត ដែលងាយស្រួលចំណាំបាន និងអាចប្រើប្រាស់បានជាព្រំប្រទល់ធម្មជាតិរបស់បណ្តាឡូតិ៍ប្រមូលផលប្រចាំឆ្នាំ ។

តំបន់ខ្លះមានការពិបាកធ្វើដំណើរទៅដល់(ភ្នំ) អាចរក្សាទុកជាតំបន់អភិរក្សសម្រាប់សត្វព្រៃ ប្រភពគ្រាប់ពូជ រុក្ខជាតិឱសថ និងតំបន់ការពារទីជម្រាលជាដើម ។ តំបន់ទាំងនេះនឹងត្រូវបានអភិរក្ស មិនអនុញ្ញាតិឲ្យធ្វើអាជីវកម្មទេ។ សារពើភ័ណ្ឌត្រូវបានធ្វើដើម្បីឲ្យដឹងថាបច្ចុប្បន្ននេះមានធនធានព្រៃឈើអ្វីខ្លះ និងធនធានអ្វីខ្លះដែលសហគមន៍ចង់បាននៅពេលអនាគត ។ តាមរយៈព័ត៍មាននេះ ការថ្លឹងថ្លែងពីដំណុះឡើងវិញពីធម្មជាតិ និង ការផែនការដកហូតឈើដោយនិរន្តរភាពនឹងត្រូវបានពិចារណា ។

## ប្រព័ន្ធប្រមូលផលទលជុំ

ក្នុងប្រព័ន្ធសុរុវុឌ្ឍកម្មព្រៃឈើ និងការប្រមូលផលព្រៃឈើវិលជុំ ព្រៃឈើត្រូវបានបែងចែកជាឡូត៍ ហើយទំហំឡូត៍នីមួយៗអាស្រ័យលើអត្រាលូតលាស់នៃព្រៃឈើ ដែលបានកំណត់ដោយការធ្វើសារពើភ័ណ្ឌធនធានព្រៃឈើ (ប្រភេទឈើមានតំលៃ និងចំណាត់ថ្នាក់ឈើតាមអាយុ) ប្រសិនបើឡូត៍ណាមួយខ្សត់ធនធាន (ដើមឈើតិចតួច) ឡូត៍នោះត្រូវតែមានទំហំធំជាង ដើម្បីរក្សាលំនឹង បរិមាណ និងគុណភាពឈើសំណាង់ នៅគ្រប់ឡូត៍ទាំងអស់ ។

រូបទី១




ឡូត៍ដកហូតប្រចាំឆ្នាំត្រូវមានតម្លៃឈើដែលត្រូវដកហូតប្រហាក់ប្រហែលគ្នា ដូច្នេះសហគមន៍អាចទទួលបានចំណូលទៀងទាត់ជារៀងរាល់ឆ្នាំ ។ ការប្រមូលផលត្រូវបានអនុញ្ញាតិតែនៅក្នុងឡូត៍ណាដែលមានដើមឈើដែលមានទំហំតាមការកំណត់ ហើយដើមឈើដែលមិនទាន់គ្រប់ខ្នាតត្រូវបន្សល់ទុកដើម្បីការលូតលាស់បន្ត ។ នៅពេលដែលឡូត៍ប្រចាំឆ្នាំចុងក្រោយត្រូវបានប្រមូលផល ការប្រមូលផលត្រូវត្រឡប់ទៅឡូត៍ប្រចាំឆ្នាំទី១វិញ (រូបទី១) ។

## ប្រព័ន្ធប្រមូលផលឈើដោយការជ្រើសរើស

ក្នុងប្រព័ន្ធប្រមូលផលឈើដោយការជ្រើសរើស ព្រៃឈើត្រូវបានរក្សាទុកទាំងមូល ដោយមិនបែងចែងជាតំបន់ទេ ។ ដើមឈើទោល ឬ ដើមឈើដុះជាក្រុម អាចអនុញ្ញាតិឲ្យកាប់ប្រចាំឆ្នាំ គឺអាស្រ័យទៅនឹងទំហំមុខកាត់នៃឈើនីមួយៗដែលកំណត់ដោយប្រភេទឈើពាណិជ្ជកម្ម ដើម្បីទទួលបានប្រាក់កំរៃជាអតិប្បរមា និងបង្កលក្ខណៈអោយដើមឈើតូចៗលូតលាស់ធំពេញវ័យជំនួសឲ្យឈើដែលបានកាប់ ។ បរិមាណឈើកាប់ប្រចាំឆ្នាំបានកំណត់ច្បាស់លាស់ដោយលទ្ធផលសារពើភ័ណ្ឌ ។ ការកាប់ឈើអាចធ្វើបានរៀងរាល់ឆ្នាំនៅគ្រប់ទីកន្លែង លើកលែងតែនៅក្នុងតំបន់អភិរក្ស (រូបទី២) ។



រូបទី២

## ការចែកចាយ ការបង់ពន្ធ និងសួយសារអាករ

ការរៀបចំផែនការគ្រប់គ្រងព្រៃឈើមួយ និងការតាមដានការអនុវត្តន៍ គឺត្រូវការចំណាយ ។ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើទទួលខុសត្រូវ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់សហគមន៍ ដែលរួមទាំងពន្ធ សួយសារអាករ និងការវិនិយោគទៅលើដីព្រៃដែលរិចរិល ។

ចំណាយបង់ពន្ធ និងសួយសារអាករសម្រាប់ឈើ ឬម៉ែត្រគូបនៃឈើដែលបានប្រមូលផល ត្រូវតែបានកត់ត្រានៅក្នុងសៀវភៅហិរញ្ញវត្ថុដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ ចំណូលនៃការបង់ពន្ធទាំងនេះគួរត្រូវបែងចែកឡើងវិញដើម្បីបែងចែកជាកញ្ចប់ ដើម្បីផ្តល់ថវិកាមួយចំនួនជូនអាជ្ញាធរមូលដ្ឋានសម្រាប់ការទ្រទ្រង់ និងសម្របសម្រួលផ្លូវច្បាប់ដល់ការកាប់ឈើ និងការដឹកជញ្ជូន ការអភិវឌ្ឍន៍មូលដ្ឋាន ដូចជា ការសាងសង់សាលារៀន ការជួសជុសផ្លូវឡើង ។ល។ និងការស្តារព្រៃឈើឡើងវិញ ៕

**កម្ពុជាហាវែស**
ផ្ទះលេខ ៤៦ ផ្លូវ ៣១០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន
ក្រុងភ្នំពេញ
ទូរស័ព្ទ ០២៣ ៩៩៦ ៤១៩
harvest@fintrac.com

ព្រឹត្តិបត្រនេះរៀបចំឡើងក្រោមការឧបត្ថម្ភពីប្រជាពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនហ្វីនត្រាក់ Fintrac Inc. និងមិនបានឆ្លុះបញ្ចាំងពីទស្សនះរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។